**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

~~~~x~~~~

**ក្រសួងពាណិជ្ជកម្ម**

**នាយកដ្ឋានកម្មសិទ្ធិបញ្ញា**

~~~~x~~~~

# របាយការណ៍ការងារ

# ប្រចាំឆ្នាំ ២០១២

# និង

# ទិសដៅការងារឆ្នាំ ២០១៣

~~*~~

ដោយមានការខិតខំព្យាយាមក្នុងការងាររបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការទាំងអស់ក្នុងនាយកដ្ឋានកម្មសិទ្ធិបញ្ញា និងដោយមានការជួយឧបត្ថម្ភគាំទ្រដ៏ថ្លៃថ្លាពីថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម ទាំងស្មារតី និងសំភារៈ រួមទាំងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយនឹងស្ថាប័នជាតិ អន្តរជាតិនានាផងនោះ ធ្វើឲ្យដំណើរការកែលម្អ និងលើកកំពស់ការអនុវត្តន៍វិស័យកម្មសិទ្ធិបញ្ញានៅកម្ពុជា កាន់តែមានភាពរឹងមាំ និង ល្អប្រសើរឡើងក្នុង ឆ្នាំ ២០១២ការរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ សេដ្ឋកិច្ចជាតិ។
សកម្មភាពជាក់ស្តែងក្នុង ឆ្នាំ ២០១២នេះ នាយកដ្ឋានទទួលបានលទ្ធផលការងារដូចខាងក្រោម:

## I- លទ្ធផលការងារដែលទទួលបាន

### 1. ការទំនាក់ទំនងសហប្រតិបត្តិការអន្តរជាតិ

**១- នាយកដ្ឋានកម្មសិទ្ធិបញ្ញា**

- ថ្ងៃទី២៣ ខែ មករា ឆ្នាំ ២០១២៖ រៀបចំលិខិតផ្ញើរជូនអគ្គនាយកអង្គការ WIPO ស្តីពីសំណើសុំឯកសារបោះពុម្ពរបស់អង្គការ WIPO ( a full set of WIPO’s Publications) ។

- ថ្ងៃទី០៣ ខែ កុម្ភៈ ឆ្នាំ ២០១២៖ រៀបចំលិខិតផ្ញើរជូន Mr. Marcelo Di Pietro Peralta ដែលជានាយកស្តីទីនៃ WIPO Academy សុំជំនួយក្នុងការបង្កើតសាលាកម្មសិទ្ធិបញ្ញាជាតិ (National Intellectual Property Academy) នៅក្នុងប្រទេសកម្ពុជា ដើម្បីពង្រឹងសមត្ថភាព និង បង្កើនការយល់ដឹងដល់សារធារណៈជន។
- ថ្ងៃទី២២ ខែ ឧសភា ឆ្នាំ ២០១២៖ រៀបចំលិខិតឆ្លើយតបជូន Mr. Johannes Christian Wichard, អគ្គនាយករងនៃអង្គការ WIPO ស្តីពីការយល់ព្រមគោរពលក្ខខណ្ឌ ដែលចែងនៅក្នុងលិខិតរបស់អង្គការ WIPO ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២ ចំពោះអង្គការ WIPO ដែលបានផ្តល់ WIPO Publications។
- ថ្ងៃទី១១ ខែ មិថុនា ឆ្នាំ ២០១២៖ រៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ខ្លួន ស្តីពីបញ្ជីសំណួរអំពី Trademark Manual ដើម្បីដាក់ជូនទៅជំនាញការអូស្ត្រាលីឆ្លើយបំភ្លឺ និងការអនុម័តលើContent នៃរបាយ ការណ៍កម្មសិទ្ធិបញ្ញា។
- ថ្ងៃទី២៣ ខែ តុលា ឆ្នាំ ២០១២៖ រៀបចំលិខិតផ្ញើរជូន Mr. William Meredith ដែលជានាយកផ្នែកដំណោះស្រាយធុរកិច្ចនៃការិយាល័យកម្មសិទ្ធិបញ្ញារបស់អង្គការ WIPO (Director of IP Office Business Solutions Division, WIPO) ដើម្បីអញ្ជើញ Dr. Juneho Jang, Head of Business Development Section មកបំពេញបេសកកម្មចាប់ពីថ្ងៃទី ១០-១១ ខែ ធ្នូ ឆ្នាំ ២០១២។

## ២- លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា

### ២-១ ការរៀបចំកិច្ចប្រជុំច្បាប់

- ថ្ងៃទី០៩ ខែ ឧសភា ឆ្នាំ ២០១២៖ រៀបចំកិច្ចប្រជុំសមាជិកលេខាធិការដ្ឋាន ដើម្បីពិនិត្យមើលសេចក្តីព្រាងច្បាប់ស្តីពី អាជ្ញាប័ណ្ណបញ្ជាសម្រាប់សុខភាពសារធារណៈ (Compulsory License for Public Health)។
- ថ្ងៃទី១៥ ខែ មិថុនា ឆ្នាំ ២០១២៖ រៀបចំកិច្ចប្រជុំសមាជិកលេខាធិការដ្ឋាន ដើម្បីកែសម្រួលច្បាប់ស្តីពីការផ្តល់អាជ្ញាប័ណ្ណបញ្ជាសម្រាប់សុខភាពសាធារណៈ ។
- ថ្ងៃទី១៦ ខែ សីហា ឆ្នាំ ២០១២៖ រៀបចំកិច្ចប្រជុំសមាជិកលេខាធិការដ្ឋាន ស្តីពី អាជ្ញាប័ណ្ណបញ្ជាសម្រាប់សុខភាពសារធារណៈ ។

### ២-២ ការរៀបចំកិច្ចប្រជុំអគ្គនាយកអង្គការ WIPO

- ថ្ងៃទី២៤ ខែ មេសា ឆ្នាំ ២០១២៖ D/IPR បានរៀបចំលិខិតដាក់ជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** ចុះហត្ថលេខាផ្ញើរជូន **សម្តេច ហ៊ុន សែន** ស្តីពីសំណើសុំអនុញ្ញាតអោយ H.E. Dr. Francis Gurry បានចូលជួបពិភាក្សា និងសំដែងការគួរសម នៅក្នុងកំឡុងពេលកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន (AEM Meeting) ចាប់ពីថ្ងៃទី ២៦-៣១ ខែ សីហា ឆ្នាំ ២០១២ នៅទីក្រុងសៀមរាប។ ***(សម្តេចអនុញ្ញាតអោយចូលជួបម៉ោង ០៨:៣០-០៩:០០ ព្រឹក ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០១២)*** ។

- ថ្ងៃទី២១ ខែ មិថុនា ឆ្នាំ ២០១២៖ D/IPR បានរៀបចំលិខិតដាក់ជូន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ស្តីពីសំណើសុំអនុញ្ញាតអោយ H.E. Dr. Francis Gurry បានចូលជួបពិភាក្សាការងារ នៅក្នុងកំឡុងពេលកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន (AEM Meeting) ចាប់ពីថ្ងៃទី ២៦-៣១ ខែ សីហា ឆ្នាំ ២០១២ នៅទីក្រុងសៀមរាប។
- ថ្ងៃទី០៧ ខែ សីហា ឆ្នាំ ២០១២៖ D/IPR បានរៀបចំលិខិតអញ្ជើញ **Ms. Pajchima Tanasanti** (AWGIPC Chair) និងជាអគ្គនាយកនៃនាយកដ្ឋានកម្មសិទ្ធិបញ្ញា ក្រសួងពាណិជ្ជកម្មប្រទេសថៃ និង សហការីរបស់គាត់ **Mr. Sila-on** ដើម្បីរាយការណ៍សង្ខេបស្តីពី ជំហររបស់អាស៊ាន ជូន**ឯកឧត្តមទេសរដ្ឋមន្ត្រី** នៅទីក្រុងសៀមរាប ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១២។

**២-៣ ការរៀបចំលិខិតសំណើសុំ**

- ថ្ងៃទី២៣ ខែ មីនា ឆ្នាំ ២០១២៖ លិខិតផ្ញើរជូន H.E. Dr. Francis Gurry ដែលជាអគ្គនាយកអង្គការ WIPO ស្តីពីវេទិការគោលនយោបាយជាតិអំពីតួនាទីនៃការច្នៃប្រឌិត និងការបង្កើតថ្មីសម្រាប់ការកសាងសមត្ថភាពបច្ចេកវិទ្យា កំណើនសេដ្ឋកិច្ច និង ការអភិវឌ្ឍ (National Policy Forum on the Role of Innovation and Creativity for Technological Capacity Building, Economic Growth and Development) ។ លិខិតនេះ ផ្តោតទៅលើសំណើសុំការគាំទ្រ៖ Preparation of National Intellectual Property and Innovation Policies and Strategies; Establishment of Technology and Innovation Support Center; Strategic Use of Branding; Identification, Documentation, Digitization of Traditional Knowledge, Traditional Cultural Expressions ។
- ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១២៖ សំណើសុំទៅអង្គការ WIPO ក្នុងការព្រាងការកសាងយុទ្ធសាស្ត្រកម្មសិទ្ធិបញ្ញាជាតិកម្ពុជា (National Intellectual Property Strategy) ។
- ថ្ងៃទី១៣ ខែ កញ្ញា ឆ្នាំ ២០១២៖ សំណើសុំរៀបចំវគ្គបណ្តុះបណ្តាលសម្រាប់អ្នកបណ្តុះបណ្តាលបន្ត (Training of Trainers Programme-TOT) ស្តីអំពីការគ្រប់គ្រងកម្មសិទ្ធិបញ្ញា ដោយសហគ្រាសធុនតូច និងមធ្យម (SMEs) ។ កម្មវិធីនេះ នឹងសហការរៀបចំ រវាងនាយកដ្ឋានកម្មសិទ្ធិបញ្ញា និងអង្គការ WIPO ។
- ថ្ងៃទី១៩ ខែ កញ្ញា ឆ្នាំ ២០១២៖ សំណើសុំគោលការណ៍ក្នុងការគាំទ្រដល់ការស្នើសុំរបស់សហរដ្ឋអាមេរិក ដើម្បីបញ្ចូលអ្នកដែលពាក់ព័ន្ធ(Stakeholders) ទៅក្នុងវេទិការពិភាក្សានានារបស់អង្គការ WIPO នៅមហាសន្និបាតអង្គការ WIPO ។
- ថ្ងៃទី០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២៖ សំណើសុំពិនិត្យលើ សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើតអនុគណៈកម្មាធិការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា និង អនុគណៈកម្មាធិការ អប់រំ និង ផ្សព្វផ្សាយ។
- ថ្ងៃទី០៥ ខែ តុលា ឆ្នាំ ២០១២៖ សំណើសុំកម្មវិធីកិច្ចប្រជុំគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញាលើកទី ៤ ។

### ២-៤ ការរៀបចំកិច្ចប្រជុំគម្រោង

លេខាធិការដ្ឋាន បានតាមដាន ប្រជុំកែសម្រួល ត្រួតពិនិត្យ និងកំពុងបន្តធ្វើគម្រោងស្តីពី ការបង្កើតប្រព័ន្ធជាតិដ៏ខ្លាំងមួយសម្រាប់ការបង្កើត កិច្ចការពារការគ្រប់គ្រង និងការអនុវត្តកម្មសិទ្ធិបញ្ញា (Development of a Stronger National System for IP Generation, Protection, Administration, and Enforcement) ។

- ថ្ងៃទី២១ ខែ ឧសភា ឆ្នាំ ២០១២៖ រៀបចំលិខិតកោះប្រជុំក្រុមការងារសសរស្តម្ភទី១ (Pillar 1) និងអនុក្រុមការងារទាំង៥ ដើម្បីពិនិត្យការអនុវត្តគម្រោង ការប្រមូលគំនិតក្នុងការបង្កើតគម្រោងថ្មី និងបណ្តុះបណ្តាលអំពីរបៀបសរសេរ និងការពិនិត្យគម្រោង។
- ថ្ងៃទី០៣ ខែ កក្កដា ឆ្នាំ ២០១២៖ រៀបចំកិច្ចប្រជុំក្រុមការងារ Pillar 1 និងអនុក្រុមការងារ ដើម្បីពិនិត្យ និងអនុម័ត លើគំរោងជាយុទ្ធសាស្ត្រដែលមានឈ្មោះថា ASYCUDA World System ដែលដាក់សំណើដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករ ។
- ថ្ងៃទី១៣ ខែ កក្កដា ឆ្នាំ ២០១២៖ រៀបចំលិខិតកោះប្រជុំក្រុមការងារ Pillar 1 និងអនុក្រុមការងារទាំង៥ ដើម្បីចូលរួមក្នុងកិច្ចប្រជុំរួមនៃក្រុម Pillar ទាំងបី ស្តីអំពីការកំនត់ និង ការបង្កើតនូវគំម្រោងសំណើជាយុទ្ធសាស្ត្រសម្រាប់ការផ្តល់មូលនិធិនាពេលបច្ចុប្បន្ន និងអនាគត នៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២។
- ថ្ងៃទី១៣ ខែ សីហា ឆ្នាំ ២០១២៖ រៀបចំកិច្ចប្រជុំ Pillar 1 ជាមួយនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ (DICO) ដោយផ្តោតទៅលើ ការលើកសំណើគម្រោងជាយុទ្ធសាស្ត្ររបស់អនុក្រុមការងារនីមួយៗ និងបទបង្ហាញរបស់ DICO លើការអនុវត្តគម្រោង ។

## ៣- កិច្ចការសហប្រតិបត្តិការ

- ថ្ងៃទី២៩ ខែ មីនា ឆ្នាំ ២០១២៖ រៀបចំកិច្ចប្រជុំ និងណាត់ជួប រវាងពាណិជ្ជករថៃ ក្រសួងមហាផ្ទៃ គយ និងកាំកុងត្រូល ស្តីពីការស្វែងយល់ប្រព័ន្ធច្បាប់កម្មសិទ្ធិបញ្ញា និងការអនុវត្តច្បាប់។
- ថ្ងៃទី២៩-៣១ ខែ ឧសភា ឆ្នាំ ២០១២៖ រៀបចំទទួលបេសកកម្មតាមដានលើរបាយការណ៍ស្តីពីការគ្រប់គ្រងរួមនៃកម្មសិទ្ធិបញ្ញា(Follow-up mission on the report on Integrated Management of IP) នៅក្នុងប្រទេសកម្ពុជា ដោយណាត់ជួបរវាង Juneho Jang ជាមន្ត្រីកម្មវិធីជាន់ខ្ពស់របស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក និងនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល គយ ក្រសួងវប្បធម៌ កាំកុងត្រូល និងប៉ូលីសសេដ្ឋកិច្ច ។
- ថ្ងៃទី៧ ខែ មិថុនា ឆ្នាំ ២០១២៖ Mr. OHKUMA Yasuo ប្រធាននាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មប្រចាំអង្គការ JETRO Bangkok បានជួបពិភាក្សាការងារជាមួយប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ដើម្បីស្វែងរកកិច្ចសហប្រតិបត្តិការបន្ថែមទៀត រវាងការិយាល័យ JPO និង ASEAN IPOs ។

- ថ្ងៃទី២៦ ខែ មិថុនា ឆ្នាំ ២០១២៖ រៀបចំកិច្ចប្រជុំពិភាក្សាជាមួយតំណាងភ្នាក់ងារមេធាវី Tilleke & Gibbins មកពីប្រទេសថៃស្តីអំពីការត្រៀមរៀបចំសិក្ខាសាលាអំពីការកំនត់សម្គាល់ទំនិញក្លែងក្លាយនៅកម្ពុជា។ កិច្ចប្រជុំនេះមានការចូលរួមពីមន្ត្រីនាយកដ្ឋានកម្មសិទ្ធិបញ្ញា មន្ត្រីគយ កាំកុងត្រូល និងក្រសួងសុខាភិបាល។
- ថ្ងៃទី០៩ ខែ សីហា ឆ្នាំ ២០១២៖ លោក Yoon Bae Kim ប្រធានសមាគមអន្តរជាតិសម្រាប់ការការពារកម្មសិទ្ធិបញ្ញា (International Association for the Protection of Intellectual Property – AIPPI) ដែលជាអង្គការអន្តរជាតិនាំមុខមួយរបស់ពិភពលោក សំដៅការអភិវឌ្ឍន៍ និងធ្វើអោយប្រសើរឡើងនូវប្រព័ន្ធការពារកម្មសិទ្ធិបញ្ញា ទាំងកម្រិតជាតិ និងអន្តរជាតិ បានមកបំពេញទស្សនកិច្ចនៅក្នុងប្រទេសកម្ពុជា ។ នៅក្នុងដំណើរទស្សនកិច្ចនេះ លោកប្រធានសមាគមបានជួបពិភាក្សាការងារជាមួយលោកប្រធាន និងមន្ត្រីនាយកដ្ឋានកម្មសិទ្ធិបញ្ញា នាយកដ្ឋានកម្មសិទ្ធិឧស្សាហម្ម នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល និងលោកប្រធានក្រុមហ៊ុនច្បាប់ BNG Legal និង HBS Law ដើម្បីស្វែងយល់អំពីប្រព័ន្ធការពារ និងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា ។
- ថ្ងៃទី១៨ ខែ តុលា ឆ្នាំ ២០១២៖ តំណាងក្រុមហ៊ុន Microsoft នៅប្រទេស Singapore និងVietnam បានជួបពិភាក្សាការងារជាមួយប្រធាន និងមន្ត្រីនាយកដ្ឋានកម្មសិទ្ធិបញ្ញា ដើម្បីស្វែងយល់អំពីក្របខណ្ឌច្បាប់កម្មសិទ្ធិបញ្ញា និងការបកស្រាយច្បាប់កម្មសិទ្ធិបញ្ញា (IPR Legal Framework and Trademark Law Interpretation) ។

## ៤- ការកសាងសមត្ថភាព (Capacity Building)

### ៤-១ ការបណ្តុះបណ្តាលក្នុងស្រុក

- ថ្ងៃទី១១-១៣ ខែ មករា ឆ្នាំ ២០១២៖ ក្រុមការងារ AWGIPC និង USPTO រួមសហការជាមួយ D/IPR រៀបចំសិក្ខាសាលា និងការពិភាក្សា ស្តីពីការត្រួតពិនិត្យម៉ាក នៅ Hotel Intercontinental ។
- ថ្ងៃទី២៨-២៩ ខែ មករា ឆ្នាំ ២០១២៖ D/IPR រួមសហការជាមួយអង្គការ WIPO រៀបចំវេទិការស្តីពីតួនាទីនៃការច្នៃប្រឌិត និងគំនិតបង្កើតថ្មី សម្រាប់ការកសាងសមត្ថភាពផ្នែកបច្ចេកវិទ្យា កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍ (The Role of Innovation and Creativity for Technological Capacity Building, Economic Growth and Development) នៅទីស្តីការក្រសួងពាណិជ្ជកម្ម ។
- ថ្ងៃទី០៥-០៧ ខែ មីនា ឆ្នាំ ២០១២៖ D/IPR បានរៀបចំវគ្គបណ្តុះបណ្តាលបញ្ចប់ ស្តីពីកម្មសិទ្ធិបញ្ញា ដែលវគ្គនេះបន្តពីវគ្គបណ្តុះបណ្តាលមុន សម្រាប់អ្នកបណ្តុះបណ្តាលបន្ត នៅទីស្តីការក្រសួងពាណិជ្ជកម្ម ។
- ថ្ងៃទី២៥ ខែ មិថុនា ឆ្នាំ ២០១២៖ D/IPR បានសហការជាមួយសមាគមធុរកិច្ចបច្ចេកវិទ្យាពត៌មាន និងគមនាគមន៍ (ICT Business Association) រៀបចំសិក្ខាសាលាស្តីពីការអនុវត្តច្បាប់ និងការរំលោភបំពានកម្មសិទ្ធិបញ្ញា ដែលធ្វើឡើងនៅទីស្តីការក្រសួងពាណិជ្ជកម្ម ។

- ថ្ងៃទី២៧ ខែ មិថុនា ឆ្នាំ ២០១២៖ ធ្វើលិខិតទៅសាកលវិទ្យាល័យមួយចំនួន ដើម្បីស្នើសុំសាស្ត្រាចារ្យ និងនិស្សិត ចុះឈ្មោះចូលរួមវគ្គបណ្តុះបណ្តាលពីចំងាយស្តីពីកម្មសិទ្ធិបញ្ញា(DL-101 General Course on Intellectual Property) ដែលរៀបចំឡើងដោយអង្គការ WIPO។
- ថ្ងៃទី២៨-២៩ ខែ មិថុនា ឆ្នាំ ២០១២៖ D/IPR បានសហការជាមួយអង្គការ WIPO រៀបចំសិក្ខាសាលាស្តីអំពីការបង្កើតមជ្ឈមណ្ឌលគាំទ្របច្ចេកវិទ្យា និងការបង្កើតថ្មី និងកម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍជំនាញ នៅទីស្តីការក្រសួងពាណិជ្ជកម្ម។ ទន្ទឹមនឹងនេះ មជ្ឈមណ្ឌលពត៌មានកម្មសិទ្ធិបញ្ញាមួយ ក៏ត្រូវបានបើកសម្ពោធអោយប្រើប្រាស់ផងដែរ ។
- ថ្ងៃទី២៣-២៧ ខែ កក្កដា ឆ្នាំ ២០១២៖ D/IPR បានសហការជាមួយអង្គការ WIPO (អ្នកជំនាញ Mr. Kumudu from WIPO and Mr. Won Seok Huh from KIPO) រៀបចំកិច្ចប្រជុំពិនិត្យ កែសម្រួល និងបំពេញនូវកង្វះខាតនានានៅក្នុងសៀវភៅណែនាំម៉ាក ព្រមទាំងផ្តល់ការបណ្តុះបណ្តាលបន្ថែម ស្តីពីការត្រួតពិនិត្យម៉ាក ជូនដល់មន្រ្តីនាយកដ្ឋានផងដែរ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ។
- ថ្ងៃទី១១ ខែ តុលា ឆ្នាំ ២០១២៖ D/IPR បានសហការជាមួយ ភ្នាក់ងារមេធាវី Tilleke & Gibbins នៅប្រទេសថៃ រៀបចំសិក្ខាសាលាស្តីពី ការកំណត់សម្គាល់ទំនិញក្លែងក្លាយ និង ទំនិញពិត នៅក្នុងប្រទេសកម្ពុជា នៅ Hotel Sofitel Phnom Penh Phokeethra ។

**៤-២ កិច្ចប្រជុំ និង ការបណ្តុះបណ្តាល ក្រៅប្រទេស**

នៅពេលថ្មីៗនេះ នាយកដ្ឋានបានបើកវគ្គបណ្តុះបណ្តាល ដើម្បីប្រលងក្លាយជាភ្នាក់ងារតំណាងម្ចាស់ម៉ាក ក្នុងរយេពេលមួយខែ ដោយបានប្រលងបញ្ចប់នៅពេលនៅពេលថ្មីៗនេះ។

ការបណ្តុះបណ្តាលក្នុង និង ក្រៅប្រទេស អ្នកចូលរួមមានចំនួន **៣៣** នាក់ នៅក្នុងកិច្ចប្រជុំ និង ការបណ្តុះ បណ្តាល សរុបចំនួន ២៦ លើក។

**(សូមមើលលំអិតក្នុងឧបសម្ព័ន្ធ) ៖**

| **អង្គភាព** | **ចំនួន** |
|---|---|
| នាយកដ្ឋានកម្មសិទ្ធិបញ្ញា ក្រសួងពាណិជ្ជកម្ម | ២៦ |
| ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ០៤ |
| ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ | ០១ |
| ក្រសួងយុត្តិធម៌ | ០១ |
| ក្រសួងអប់រំ | ០១ |

## ២- ការសម្គាល់ភូមិសាស្ត្រទំនិញ

### ក១- ក្នុងក្របខ័ណ្ឌក្រសួងពាណិជ្ជកម្ម ច្បាប់ ស្តីពី " ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ "

ការសម្គាល់ភូមិសាស្ត្រទំនិញ និងពត៌មានសម្ងាត់ពាណិជ្ជកម្មសម្រេចបាននូវកិច្ចការរៀបចំ ច្បាប់ និងបទបញ្ញត្តិនានា ដូចខាងក្រោម :

**ក១-១**-សេចក្តីព្រាងច្បាប់ ស្តីពី ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ បានប្រជុំចង្អៀត ចំនួន**០៦**លើកគឺ នៅទីស្តីការក្រសួងពាណិជ្ជកម្មចំនួន**០១**លើក និង នៅទីស្តីការគណៈរដ្ឋមន្ត្រីចំនួន**០៥**លើក ប្រជុំបច្ចេកទេស ចំនួន **០២** លើកនៅទីស្តីការគណៈរដ្ឋមន្ត្រី និងប្រជុំអន្តរក្រសួងចំនួន០១លើកនៅទីស្តីការគណៈរដ្ឋមន្ត្រី។ ច្បាប់នេះបានត្រៀមលក្ខណៈរួចរាល់ហើយដើម្បីឆ្លងក្នុងសម័យប្រជុំពេញអង្គរបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងត្រៀមបញ្ជូនទៅរដ្ឋសភាជាតិ ដើម្បី អនុម័តជាផ្លូវការ នាពេលឆាប់ៗខាងមុខ ។

## ខ. ការងារផ្សព្វផ្សាយ និង សហប្រតិបត្តិការអន្តរជាតិ

### ខ១- ការងារបណ្តុះបណ្តាល

ការសម្គាល់ភូមិសាស្ត្រទំនិញ និង ពត៌មានសម្ងាត់ពាណិជ្ជកម្ម បានបើកវគ្គបណ្តុះបណ្តាល ស្តីពី ម៉ាកសម្គាល់លើភូមិសាស្ត្រទំនិញ ដល់មន្ត្រីនាយកដ្ឋានកម្មសិទ្ធិបញ្ញាទាំងអស់ ដើម្បីឲ្យពួកគេកាន់តែមានមូលដ្ឋានចំណេះដឹងខ្ពស់ និងស្វែងយល់អំពីទស្សនទាននៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ក្នុងការលើកស្ទួយ និង ការ ការពារទំនិញសម្គាល់ភូមិសាស្ត្រ ។

### ខ១-១- ការងាររៀបចំសិក្ខាសាលាក្នុងប្រទេស :

| | | |
|---|---|---|
| | -បានធ្វើសិក្ខាសាលាក្នុងស្រុក ចំនួន | : ០១ លើក |
| | -សរុបសិក្ខាកាម | : ៥៧ នាក់ |
| ក្នុងនោះ : | -មន្ត្រីការិយាល័យចំនួន | : ០៥ នាក់ |
| | -មន្ត្រីការិយាល័យពាក់ព័ន្ធចំនួន | : ២៧ នាក់ |
| | -មន្ត្រីក្រសួងនិងស្ថាប័នពាក់ព័ន្ធចំនួន | : ០៧ នាក់ |
| | -តំណាងសមាគមចំនួន | : ១១ នាក់ |
| | -ជនបរទេសចំនួន | : ០៧ នាក់ |

### ខ១-២- បញ្ជូនមន្ត្រីជំនាញទៅធ្វើកម្មសិក្សា នៅក្រៅប្រទេស :

| | | |
|---|---|---|
| | -សរុបចំនួនកម្មសិក្សា ដែលបានទៅចូលរួម | : ០៣ លើក |
| ក្នុងនោះ : | -មន្ត្រីការិយាល័យចំនួន | : ០៧ នាក់ |
| | -មន្ត្រីការិយាល័យពាក់ព័ន្ធចំនួន | : ០២ នាក់ |

## ៣- កិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ

### -ធនធានមនុស្ស

នាយកដ្ឋានមានមន្ត្រីរាជការសរុបចំនួន ៦៣នាក់ ក្នុងនោះ មន្ត្រីរាជការថ្នាក់នាយកដ្ឋានមាន ចំនួន០៥ នាក់ និង ថ្នាក់ការិយាល័យមានចំនួន ២៦នាក់។

**-ការងារថវិកា**

ក្នុងឆ្នាំ២០១២នេះ នាយកដ្ឋានបានរកចំណូលថវិកាបង់ជូន នាយកដ្ឋានរដ្ឋបាលរបស់ក្រសួងសរុប ចំនួន **១.២៧0.២៨0000,00៛** ដែលក្នុងនោះរួម មាន៖

-កំរៃនៃការដាក់ពាក្យសុំចុះបញ្ជីម៉ាក : ១០២,៨០០,០០០.០០៛
-កំរៃនៃការចុះបញ្ជីម៉ាក : ៦២៨,៦២០,០០០.០០៛
-កំរៃនៃការបញ្ជាក់ ការប្រើប្រាស់បញ្ជីម៉ាក : ៩១,០០០,០០០.០០៛
-កំរៃនៃការផ្ទេរកម្មសិទ្ធិម៉ាក : ១៣,៦៤០,០០០.០០៛
-កំរៃនៃការប្តូរឈ្មោះម្ចាស់ម៉ាក : ៣៦,២០០,០០០.០០៛
-កំរៃនៃការកែតម្រូវនានា : ៨០០,០០០.០០៛
-កំរៃនៃការក្នុងការប្តូរអាស័យដ្ឋាន : ២៤,០៤០,០០០.០០៛
-កំរៃក្នុងការលុបម៉ាកចេញពីបញ្ជី : ៨០០០,០០០.០០៛
-កំរៃនៃការចុះបញ្ជីសារឡើងវិញ : ៣៧២,៨០០,០០០.០០៛

សរុប: ១,២៧០,២៨០,០០០.០០៛

## តារាងប្រៀបធៀបចំណូលឆ្នាំ២០១១ នឹងឆ្នាំ២០១២

| លរ | បរិយាយមុខចំណូល | | ការប្រៀបធៀបចំណូល | | | | |
|---|---|---|---|---|---|---|---|
| | | | សរុបចំណូលឆ្នាំ២០១១ | | សរុបចំណូលឆ្នាំ២០១២ | | ភាគរយ |
| ១ | ដាក់ពាក្យ | ក្នុងស្រុក | ៨០៦ | ១៦.១២០.០០០ | ៩០៦ | ១៨.១២០.០០០ | ១២,៤% |
| | | ក្រៅស្រុក | ៣៦៥៣ | ៧៣.០៦០.០០០ | ៤២៣៤ | ៨៤.៦៨០.០០០ | ១៥,៩% |
| | | **សរុប** | **៤៤៥៩** | **៨៩.១៨០.០០០** | **៥១៤០** | **១០.៨០០.០០០** | **១៥,៣%** |
| ២ | ចុះបញ្ជីម៉ាក | ក្នុងស្រុក | ៦៥៤ | ១១៧.៧២០.០០០ | ៧០៥ | ១២៦.៩០០.០០០ | ៧,៨% |
| | | ក្រៅស្រុក | ៣០០៥ | ៥៤.៩០០.០០០ | ២៧៨៥ | ៥០១.៣០០.០០០ | -៧,៣% |
| | | **សរុប** | **៣៦៥៩** | **៦៥៨.៦២០.០០០** | **៣៤៩០** | **៦២៨.២០០.០០០** | **-៤,៦%** |
| ៣ | ការបញ្ជាក់លើការប្រើប្រាស់ រឺមិនបានប្រើប្រាស់ | | ១៦៤១ | ៦៥.៦៤០.០០០ | ២២៧៥ | ៩១.០០០.០០០ | ៣៨,៦% |
| ៤ | ការផ្ទេរសិទ្ធិម្ចាស់ម៉ាក | | ៤៤៣ | ១៧.៧២០.០០០ | ៣៤១ | ១៣.៦៤០.០០០ | -២៣,០% |
| ៥ | ការប្តូរឈ្មោះ រឺបញ្ចូលគ្នានៃម្ចាស់ម៉ាក | | ៤៦៧ | ១៨.៦៨០.០០០ | ៩០៥ | ៣៦.២០០.០០០ | ៩៣,៨% |
| ៦ | ការកែតម្រូវនានា | | ៤២ | ១.៦៨០.០០០ | ២០ | ៨០០.០០០ | -៥២,៤% |
| ៧ | ការប្តូរឈ្មោះអាសយដ្ឋាន | | ៣៣៧ | ១៣.៤៨០.០០០ | ៦០១ | ២៤.០៤០.០០០ | ៧៨,៣% |
| ៨ | ការលុបម៉ាក | | ១៧ | ៣.៤០០.០០០ | ៤ | ៨០០.០០០ | -៧៦,៥% |
| ៩ | ការចុះបញ្ជីម៉ាកសារឡើងវិញ | | ៨៧៨ | ១៧៥.៦០០.០០០ | ១៨៦៤ | ៣៧២.៨០០.០០០ | ១១២% |
| **សរុប** | | | | **១,០៩៤,០០០,០០០** | | **១,២៧០,២៨០,០០០** | **២១,៧ %** |

**សន្និដ្ឋានៈ**

ក្នុងឆ្នាំ២០១២នេះ នាយកដ្ឋានបានបង់ចំណូលថវិការដ្ឋ ជូននាយកដ្ឋានរដ្ឋបាលបានទឹកប្រាក់ បានចំនួន **១,២៧០,២៧០,០០០៛** បើប្រៀបធៀបទៅនឹងការបង់ចំណូលថវិកា ជូនរដ្ឋឆ្នាំ២០១១ ទឹកប្រាក់ចំនួន **១,០៤៤,០០០,០០០៛** ឃើញថាមានការកើនឡើង **២១,៧%**។ ប៉ុន្តែបើប្រៀបធៀបទៅនឹងផែនការ រកចំណូលឆ្នាំ២០១២ ទឹកប្រាក់ចំនួន **១,០៦២,៥៤០,០០០៛** នាយកដ្ឋានរកចំណូលជូនរដ្ឋបានលើសផែនការ **២១,៧%**។

## ៤-កិច្ចការជំនាញ

**ការចុះបញ្ជីម៉ាក**

**-ទទួលពាក្យស្នើសុំចុះបញ្ជីម៉ាក**

នាយកដ្ឋានបានទទួលពាក្យស្នើសុំចុះបញ្ជីសរុបចំនួន **៥១៤០** ម៉ាក ក្នុងនោះម៉ាក

-ក្នុងស្រុកចំនួន **៩០៦** ម៉ាក

-ក្រៅស្រុកចំនួន **៤២៣៤** ម៉ាក

ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ឆ្នាំ២០១២ សរុបបានចំនួន **៥១៤០** ម៉ាក ហើយបើប្រៀបធៀប ទៅនឹងរយៈពេលដូចគ្នាឆ្នាំ ២០១១ ដែលទទួលបានចំនួន **៤៤៥៩** ម៉ាក ឃើញថាមានការកើនឡើងចំនួន **៦៨១ ម៉ាក** ស្មើនឹង **១៥,៣%** ។

**ឯកភាពចុះបញ្ជីម៉ាកស្នើសុំថ្មី**

នាយកដ្ឋានបានឯកភាពចុះបញ្ជីជូនអតិថិជនសរុបចំនួន **៣៤៩០** ម៉ាក ក្នុងនោះម៉ាក

-ក្នុងស្រុកចំនួន **៧០៥** ម៉ាក

-ក្រៅស្រុកចំនួន **២៧៨៥** ម៉ាក

ក្នុងឆ្នាំ ២០១២ នាយកដ្ឋានបានឯកភាពចុះបញ្ជីម៉ាក បានចំនួន **៣៤៩០** ម៉ាក ហើយបើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាឆ្នាំ ២០១១ ចុះបញ្ជីបានចំនួន**៣៦៥៩ ម៉ាក** ឃើញថាមានការថយចុះចំនួន **១៦៩** ម៉ាក ស្មើនឹង **-៤,៦%** ។

**កិច្ចការក្រោយចុះបញ្ជីម៉ាក**

-ការដាក់ពាក្យ និងការបញ្ជាក់ពាក្យប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាក(Affidavit) **២២៧៥**

-ការកត់ត្រា កាផ្ទេរសិទ្ធិម៉ាក (Assignment) **៣៤១**

-ការកត់ត្រា ការប្តូរឈ្មោះ ឬបញ្ចូលគ្នានៃម្ចាស់ម៉ាក (Name Change and Merger) **៩០៥**

-ការកែតំរូវនានា(Amendment) **២០**

-ប្តូរអាសយដ្ឋាន (Change Address) **៦០១**

-ការលុបម៉ាកចេញពីបញ្ជី **៤**

-ចុះបញ្ជីសាឡើងវិញ (Renewal) **១៨៦៤**

-ថ្មីៗនេះដែល នាយកដ្ឋានបានរៀបចំ Search ក្រុមហ៊ុនជូននាយកដ្ឋានចុះបញ្ជីបានចំនួន ៤៦៥ ក្រុមហ៊ុន។

### ការងារបោះពុម្ពផ្សាយព្រឹត្តិប័ត្រផ្លូវការ

ក្នុងឆ្នាំ២០១២ នាយកដ្ឋានបានបោះពុម្ពព្រឹត្តិប័ត្រផ្លូវការ (Offocial Gazette) បានសរុបចំនួន ១២លេខ គឺចាប់ពីលេខ ១៤២ ដល់ ១៤៧ ដើម្បីសំរាប់ផ្សព្វផ្សាយជាសាធារណៈ។

## ៥-ការដោះស្រាយវិវាទរំលោភបំពានកម្មសិទ្ធិបញ្ញា និងការលុបម៉ាកចេញពីបញ្ជី

ក) ការងារទទួលពាក្យ

នៅក្នុងឆ្នាំ ២០១២ នេះ នាយដ្ឋានបានទទួលពាក្យបណ្តឹងសរុបចំនួន **៤៣**ករណី ស្មើ **៤៧**ម៉ាក ក្នុងនោះរួមមាន ពាក្យស្នើសុំទប់ស្កាត់ការរំលោភបំពាន (សូមមើលតារាង ANNEX I) មានចំនួន **១៥**ករណី ស្មើ **១៥**ម៉ាក ពាក្យស្នើសុំបញ្ជាក់ សុពលភាព និងប្រៀបធៀបម៉ាក មានចំនួន **១៤**ករណី ស្មើ **១៧**ម៉ាក និងពាក្យស្នើសុំលុប ម៉ាក (សូមមើលតារាង ANNEX II) មានចំនួន **១៤**ករណី ស្មើ **១៥**ម៉ាក ។

ខ) លទ្ធផលនៃការដោះស្រាយ

១-ការដោះស្រាយការរំលោភបំពាន

ក្នុងឆ្នាំ ២០១២ នេះ នាយដ្ឋានបានពិនិត្យពាក្យបណ្តឹងចំនួន **៣៨**ករណី (ក្នុងឆ្នាំ ២០១២ ទទួលបានចំនួន **១៥**ករណី និងសល់ពីឆ្នាំ ២០១១ **៩**ករណី) និងបានដោះស្រាយការរំលោភបំពាន បានចំនួន **២៤**ករណី ក្នុងនោះរួមមាន ការធ្វើការសំរបសំរួលដោយមានកំណត់ហេតុចំនួន **៨**ករណី ធ្វើលិខិតបញ្ជាក់ពីភាពស្រដៀង និងសុពលភាពប្រើប្រាស់ម៉ាកមានចំនួន **១២**ករណី បដិសេធ ពាក្យបណ្តឹងចំនួន **៤**ករណី ហើយនៅសល់ **១៤**ករណីទៀត ការិយាល័យកំពុងបន្តពិនិត្យ និង ដោះស្រាយ (សូមមើលតារាង ANNEX I)។

២-ការលុបម៉ាកចេញពីបញ្ជី

ក្នុងឆ្នាំ ២០១២នេះ ការិយាល័យវិវាទបានពិនិត្យពាក្យស្នើសុំលុបម៉ាកចំនួន **៣៤**ករណី ស្មើ **៤៥**ម៉ាក (ក្នុងឆ្នាំ ២០១១២ ទទួលបាន **១៤**ករណី ស្មើ **១៥**ម៉ាក និងនៅសល់ពីឆ្នាំ ២០១១ ចំនួន **២០**ករណី ស្មើ **៣០**ម៉ាក) និងបានដោះស្រាយចំនួន **៨**ករណី ស្មើ **៩**ម៉ាក ក្នុងនោះរួមមាន ការលុបម៉ាកចេញពីបញ្ជីចំនួន **៣**ករណី ស្មើ **៤**ម៉ាក កែតម្រូវម៉ាកសារជាថ្មីចំនួន **១**ករណី ស្មើ **១**ម៉ាក ផ្ទេរសិទ្ធិចំនួន **១**ករណី ស្មើ **១**ម៉ាក និងសុំដកពាក្យ **៣**ករណី ស្មើ **៣**ម៉ាក ហើយនៅសល់ **២៦**ករណី ស្មើ **៣១**ម៉ាក ការិយាល័យកំពុងបន្ត ពិនិត្យ និងដោះស្រាយ (សូមមើលតារាង ANNEX II) ។

គ) ការប្រៀបធៀប

បើធ្វើការប្រៀបធៀបការទទួលពាក្យស្នើសុំទប់ស្កាត់ការរំលោភបំពានកម្មសិទ្ធិបញ្ញា ក្នុងឆ្នាំ ២០១២ នេះ នឹងឆ្នាំ ២០១១ គឺថយចុះចំនួន **១១**ករណី ឬថយចុះ **៤២.៣%** ហើយការទទួលពាក្យ ស្នើសុំលុបម៉ាកចេញពីបញ្ជីមានការថយចុះចំនួន **២**ករណី ឬថយចុះ **១២.៥%** ។ ចំណែកលទ្ធផល នៃការដោះស្រាយ

ការរំលោភបំពានក្នុងឆ្នាំ ២០១២ មានចំនួន **២៤**ករណី បើធៀបនឹងឆ្នាំ ២០១១ គឺមានការកើនឡើង **៤**ករណី ឬកើនឡើង **២០%** ។ ដោយឡែកការលុបម៉ាកចេញពីបញ្ជីក្នុងឆ្នាំ ២០១២នេះ មានចំនួន **៤**ម៉ាក បើធៀបនឹងឆ្នាំ ២០១១ គឺមានការថយចុះចំនួន **១៣**ម៉ាក ឬថយចុះ **៧៦.៥%** ។

ក្រាហ្វិកប្រៀបធៀប ឆ្នាំ ២០១**២** ធៀបទៅនឹងឆ្នាំ ២០១១ និង ២០**១០**




ទោះបីសកម្មភាពរំលោភបំពានម៉ាក នៅក្នុងឆ្នាំ ២០១២ មានការកើនឡើងក៏ដោយ ក៏មិន មែនជាសូចនាករមួយឆ្លុះបញ្ចាំងពីសកម្មភាពរំលោភបំពានកម្មសិទ្ធិបញ្ញា នៅក្នុងប្រទេសកម្ពុជាទាំងមូលនោះឡើយ ប៉ុន្តែវាជាសូចនាករមួយជ្រុង បង្ហាញឲ្យឃើញថា សកម្មភាព រំលោភបំពាន នៃម៉ាក មានការកើនឡើង ហើយសកម្មភាពពាណិជ្ជកម្មមានភាពលូតលាស់ បានប្រសើរឡើងដែរ ទន្ទឹមនឹងនេះ ការយល់ដឹងផ្នែកកម្មសិទ្ធិបញ្ញា ក្នុងប្រទេសកម្ពុជា បានចាប់ផ្តើមជ្រាបចូលក្នុង ស្រទាប់មហាជនកាន់តែប្រសើរឡើង ហើយម្ចាស់កម្មសិទ្ធិបញ្ញា បានចាប់អារម្មណ៍ដល់ការការពារ ផលប្រយោជន៍ ដែលខ្លួនជាម្ចាស់កម្មសិទ្ធិ ដោយផ្តួចផ្តើម ចាត់វិធានការចំពោះការរំលោភបំពាន ទាំងនោះ ទៅតាមស្ថាប័នអនុវត្តកម្មសិទ្ធិបញ្ញា ដែលមានស្រាប់ ។

## សន្និដ្ឋាន

ថ្វីត្បិតតែនាយកដ្ឋានកម្មសិទ្ធិបញ្ញា ខិតខំបំពេញការងាររបស់ខ្លួនបាននាំមកនូវការវិវត្តន៍ ដ៏ប្រសើរក៏ដោយ ក៏នាយកដ្ឋាន នៅមានការងារជាច្រើនទៀត ត្រូវបំពេញឲ្យបានទាន់ ការវិវត្តន៍ នៃកម្មសិទ្ធិបញ្ញាជាសកល និងការរីករាលដាល នៃការរំលោភបំពានកម្មសិទ្ធិបញ្ញា ដូច្នេះទាមទារឲ្យមានមន្ត្រី ដែលមានសមត្ថភាព មកបំរើការងារ បន្ថែមទៀត ។

សកម្មភាពរំលោភបំពានកម្មសិទ្ធិបញ្ញានៅក្នុងប្រទេសកម្ពុជា នៅតែជាបញ្ហាគួរឲ្យកត់សម្គាល់នៅឡើយ ហើយការអនុវត្តន៍កម្មសិទ្ធិបញ្ញា មិនអាចប្រព្រឹត្តទៅដោយរលូនបានទេ ប្រសិនបើម្ចាស់ កម្មសិទ្ធិបញ្ញា នៅតែប្រងើយកន្តើយចំពោះការរំលោភបំពានទាំងនោះ គួរតែម្ចាស់កម្មសិទ្ធិបញ្ញាទាំងនោះ សហការជាមួយ អាជ្ញាធរមានសមត្ថកិច្ច ដើម្បីធ្វើការទប់ស្កាត់ ការរំលោភបំពានឲ្យកាន់តែមានប្រសិទ្ធិភាព លើកស្ទួយការបង្កើន សម្បត្តិកម្មសិទ្ធបញ្ញា ក្នុងការចូលរួម ចំណែក អភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។

តារាង ANNEX I

| ស្ថិតិការរំលោភបំពានម៉ាកក្នុងឆ្នាំ ២០១២ | | | | |
|---|---|---|---|---|
| | | ការដោះស្រាយ | | |
| ឆ្នាំ | ការទទួលពាក្យបណ្តឹង | ការដក និង បដិសេធ ពាក្យបណ្តឹង | ការបញ្ជាក់ផ្សេងៗ ចេញលិខិតព្រមាន កែតម្រូវ សំរបសំរួល និងបញ្ជាក់ភាពស្រដៀង | នៅសល់ |
| ២០១១ | | | | ៩ |
| ២០១២ | ២៩ | ៤ | ២០ | |
| សរុប | ៣៨ | ៤ | ២០ | ១៤ |

តារាង ANNEX II

| ស្ថិតិនៃការលុបម៉ាកក្នុងឆ្នាំ ២០១២ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ឆ្នាំ | ការទទួលពាក្យបណ្តឹង | | ការដោះស្រាយ | | | | | | នៅសល់ | |
| | | | ការបដិសេធន៍ និងដកពាក្យបណ្តឹង | | លុប | | ផ្ទេរសិទ្ធិ និង កែតម្រូវ | | | |
| | ករណី | ម៉ាក | ករណី | ម៉ាក | ករណី | ម៉ាក | ករណី | ម៉ាក | ករណី | ម៉ាក |
| ២០១១ | | | | | | | | | ២០ | ៣០ |
| ២០១២ | ១៤ | ១៥[១] | ៣ | ៣ | ៣ | ៤ | ២ | ២ | | |
| សរុប | ៣៤ | ៤៥[២] | ៣ | ៣ | ៣ | ៥[៣] | ២ | ២[៤] | ២៦ | ៣១ |

## II- ទិសដៅអនុវត្តការងារសម្រាប់ឆ្នាំ ២០១២

**ក១**-នាយកដ្ឋាននឹងត្រៀមបញ្ជូនលិខិតស្នើសុំ ទៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអ្នកច្បាប់នៃ ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីជួយរៀបចំ កិច្ចប្រជុំបច្ចេកទេសលើសេចក្តីព្រាងច្បាប់ ស្តីពី **៉ម៉ាកសម្គាល់ ភូមិសាស្ត្រ ទំនិញ៉** នេះ បន្តទៀត។

ក១-រៀបចំសេចក្តីព្រាងអនុក្រឹត្យ និងប្រកាស ក្នុងការអនុវត្តច្បាប់ស្តីពី **"ម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ"** ។

**ខ-ការងារបច្ចេកទេស និងកិច្ចសហប្រតិបត្តិការ**

**ខ១**-ត្រៀមរៀបចំបង្កើយនីតិវិធីពាក់ព័ន្ធនានា ដើម្បីត្រៀមទទួលពាក្យស្នើសុំចុះបញ្ជីម៉ាក សមូហភាព (Collective Mark) នាពេលដ៏ខ្លីខាងមុខនេះ ។

**ខ២**-រៀបចំ និង ត្រៀមធ្វើសហប្រតិបត្តិការជាមួយ International Finance Corporation (IFC)និង ធនាគារពិភពលោក (World Bank) ដើម្បីស្នើសុំថវិកាមកអនុវត្តគម្រោងលើផលិតផល សក្តានុពលចំនួន ០១ មុខ គឺ អង្ករបាត់ដំបង ជាម៉ាកសមូហភាព ។

**ខ៣**-បន្តសហការជាមួយអាជ្ញាធរដែនដី និងក្រសួងជំនាញដែលមានការពាក់ព័ន្ធ ដើម្បីធ្វើការសិក្សាស្រាវជ្រាវ និងកំណត់តំបន់ភូមិសាស្រ្តផលិតផលដែលមានសក្តានុពល ដើម្បីឈានទៅដល់ការចុះបញ្ជីការពារជាផលិតផលសម្គាល់ភូមិសាស្រ្ត នាថ្ងៃអនាគត ។

**ខ៤**-ជម្រុញការសិក្សាបន្ថែម និង ស្វែងរកដៃគូផ្តល់ជំនួយ លើផលិតផលដែលបានកំណត់ អត្តសញ្ញាណរួចហើយដូចជា អង្ករនាងអំក្រចេះ អង្ករបាត់ដំបង ប្រហុកសៀមរាប ក្រូចពោធិសាត់ ក្រវ៉ាញពោធិសាត់ ស្ករត្នោតកំពង់ស្ពឺ ទឹកឃ្មុំមណ្ឌលគីរី ធូរេនកំពតជាដើម ដើម្បីឈានទៅរកការចុះបញ្ជីការពារម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ ។

**ខ៥**-រៀបចំសិក្ខាសាលាផ្សព្វផ្សាយទស្សនាទានផលិតផលសម្គាល់ភូមិសាស្រ្ត ក្រោមច្បាប់ស្តីពី "ម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ" នៅពេលដែលច្បាប់នេះត្រូវបានអនុម័តដោយរដ្ឋសភារួចហើយ ក្នុងគោលដៅជម្រុញការចុះបញ្ជីផលិតផលសម្គាល់ភូមិសាស្រ្តទាំងក្នុង និងក្រៅប្រទេស។

**ខ៦**-ត្រៀមរៀបចំធ្វើកិច្ចសហប្រតិបត្តិការជាមួយទីភ្នាក់ងារបារាំងដើម្បីការអភិវឌ្ឍន៍(AFD) និង អង្គការស្បៀងអាហារ និងកសិកម្មពិភពលោក (FAO, Food and Agriculture of the United Nation) ដើម្បីអនុវត្តគម្រោងថ្នាក់តំបន់ ស្តីពី សម្គាល់ភូមិសាស្រ្តទំនិញ ដែលមានសមាជិកចំនួន ០៤ ប្រទេស គឺ កម្ពុជា វៀតណាម ឡាវ និង ថៃ ក្នុងគោលបំណងផ្លាស់ប្តូរបទពិសោធន៍ និង ផ្លាស់ប្តូរចំណេះដឹងរវាងប្រទេសជាសមាជិកក្នុងវិស័យសម្គាល់ភូមិសាស្រ្តទំនិញ នាពេលខាងមុខនេះ។

- ជំរុញដោះស្រាយរាល់វិវាទទាក់ទិននឹង ការរំលោភបំពាន និងការលុបម៉ាក ដែលនៅ សេសសល់ ។
- បន្តបង្កើនកិច្ចសហការឲ្យកាន់តែជិតស្និទ្ធ និងមានលក្ខណៈកាន់តែប្រសើរឡើងថែម ទៀតជាមួយអង្គភាពពាក់ព័ន្ធ និងស្ថាប័នមានសមត្ថកិច្ចនានា ដើម្បីកាត់បន្ថយការ រំលោភបំពានកម្មសិទ្ធិបញ្ញាឲ្យបានជាអតិបរិមា ។
- រៀបចំរាល់ឯកសារឲ្យកាន់តែមានរបៀបរៀបរយ ។
- បន្តតាមដានលក្ខខ័ណ្ឌដល់ការចុះបញ្ជីម៉ាក ដែលមានវិវាទ ក្នុងប្រព័ន្ធ IPAS ដើម្បីធានាដល់ប្រសិទ្ធិភាពការងាររបស់ការិយាល័យចំណុះនាយកដ្ឋានកម្មសិទ្ធិបញ្ញា ។
- បង្កើនសមត្ថភាពយល់ដឹង លើផ្នែកភាសាអង់គ្លេស កុំព្យូទ័រនិងកម្មសិទ្ធិបញ្ញា ដល់មន្រ្តី ក្នុងការនាយកដ្ឋាន តាមរយៈការបញ្ជូនទៅសិក្សាទាំងនៅក្នុង និងក្រៅប្រទេស ។
- បន្តរក្សាសាមគ្គីភាពផ្ទៃក្នុងឲ្យបានល្អ រវាងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ ។

ភ្នំពេញ,ថ្ងៃទី២៥ ខែ ធ្នូ ឆ្នាំ២០១២

**អនុប្រធាននាយកដ្ឋាន**

ស៊ីម សុខខេង